
ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ
តើធ្វើដូចម្តេចដើម្បីឱ្យការអភិវឌ្ឍន៍កសិកម្ម
អាចចូលរួមកាត់បន្ថយភាពក្រីក្របាន ?

# ការអភិវឌ្ឍន៍កសិកម្មក្នុងបុព្វបទនៃការកាត់បន្ថយភាពក្រីក្រ

- តើភាពក្រីក្របណ្ដាលមកពីមូលហេតុអ្វី ? ភាពក្រីក្របណ្ដាលមកពីការគ្មានឱកាសគ្រប់គ្រាន់ ជាពិសេសគឺឱកាសក្នុងសកម្មភាពកសិកម្ម និងសកម្មភាពផ្សេងៗ ទៀតដែលពាក់ព័ន្ធទៅដល់ការប្រកបរបរចិញ្ចឹមជីវិតនៃប្រជាពលរដ្ឋនៅទីជនបទ ។
- ប្រជាជនប្រមាណជា ៨៥ ភាគរយ រស់នៅទីជនបទ ហើយពួកគាត់ប្រកបរបរចិញ្ចឹមជីវិតដោយពឹងអាស្រ័យទាំងស្រុងលើរបរកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិរួមផ្សំ ។ ជាពិសេស ធនធាន ជលផល និងព្រៃឈើ ។
- កសិកម្មជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចជាតិ ដែលបានចូលរួមចំណែកក្នុងផលទុនជាតិប្រមាណជា ៤៥.៦ ភាគរយ នៅចន្លោះឆ្នាំ ៩៣ - ២០០១ និងបានថយចុះមកនៅត្រឹម ៣០.១ ភាគរយ ក្នុងឆ្នាំ ២០០៥ ក្នុងនោះផលិតផលកសិកម្មមានចំនួន ១៤.២ ភាគរយ ផលិតកម្មបសុព្យាបាល ៤.៦ ភាគរយ ជលផល ៩.៣ ភាគរយ និង ២ ភាគរយ បានមកពីព្រៃឈើ ។

# តើការអភិវឌ្ឍន៍កសិកម្មចូលរួមយ៉ាងដូចម្តេចក្នុងការកាត់បន្ថយភាពក្រីក្រ ? (ត)

- យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍន៍វិស័យកសិកម្មបានផ្តោតសំខាន់ទៅលើការបង្កើតនូវបរិបទដែលមានភាពងាយស្រួលសំរាប់ជំរុញកំនើនផលិតភាពកសិកម្ម ។ ការប្រឹងប្រែងបានបង្កើននូវសក្តានុពលភាព និងការធ្វើទំនើបភាវូបនីយកម្មកសិកម្មដោយជំរុញបង្កើន ការងារ និងប្រាក់ចំនូលគ្រួសារជាពិសេសបង្កើនស្បៀងអាហារឱ្យបានគ្រប់គ្រាន់ ។
- ការធ្វើទំនើបភាវូបនីយកម្មកសិកម្មទាមទារនូវការគាំទ្រដល់កសិករក្នុងការធ្វើកសិកម្មទ្រង់ទ្រាយតូចតាមបែបនៃការប្រើប្រាស់បច្ចេកទេសសមស្របដែលកសិករអាចត្រួតពិនិត្យបាននូវផលិតភាព និងលក្ខខណ្ឌបរិស្ថានផលិតកម្ម ។ ក្នុងដំណោះស្រាយនេះរួមមាន : ការបញ្ចូលនូវប្រព័ន្ធគាំទ្រផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងទំរង់គោលនយោបាយកសិកម្មដែលសម្រួលដល់ការចូលរួមពីផ្នែកឯកជន ។ ទន្ទឹមនោះ ការវិនិយោគសាធារណៈ និងការវិនិយោគឯកជន គួរមានការលើកទឹកចិត្តក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងទំនិញរួមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស ។

# តើការអភិវឌ្ឍន៍កសិកម្មចូលរួមយ៉ាងដូចម្តេចក្នុងការកាត់បន្ថយភាពក្រីក្រ ? (ត)

- ការអភិវឌ្ឍន៍កសិកម្មបានផ្តោតការយកចិត្តទុកដាក់ដោយបង្កើនការទទួលខុសត្រូវ របស់កសិករក្រីក្រនៅជនបទ ដើម្បីបង្កលទ្ធភាពឱ្យពួកគេបានចូលរួមក្នុងដំណើការអភិវឌ្ឍន៍ ។ កិច្ចការនេះត្រូវបានផ្តើមឡើងពីការជំរុញឱ្យពួកគាត់មានដីធ្លី ទឹកប្រើប្រាស់ និងបណ្តាមធ្យោបាយផលិតកម្មផ្សេងៗទៀត ដើម្បីសុវត្ថិភាពក្នុងការចិញ្ចឹមជីវិត និងការអភិវឌ្ឍន៍សង្គម ។

# តើក្រសួងណាខ្លះដែលមានការពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍កសិកម្ម ?

ស្ថាប័នរាជរដ្ឋាភិបាលជាច្រើនដែលមានការពាក់ព័ន្ធបាន និង កំពុងចូលរួមក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មរួមមាន:

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ....... ។ល ។

# តើការអភិវឌ្ឍន៍កសិកម្ម គួរធ្វើក្នុងកំរិតណា ?

ការអភិវឌ្ឍន៍កសិកម្ម គួរត្រូវបានកំនត់ច្បាស់លាស់ក្នុងរង្វង់ ៖

- រៀបចំទំរង់ការសមស្របនៃម៉ាក្រូសេដ្ឋកិច្ច ស្របតាមគោលនយោបាយ និងបរិស្ថានស្ថាប័ន
- បង្កើនល្បឿនអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពដោយនិរន្តរភាព
- អភិវឌ្ឍន៍ទីផ្សារនាំចេញស្រូវ និងផលិតផលផ្សេងៗទៀត ដូចជា៖ ការកែច្នៃ និងការត្រួតពិនិត្យគុណភាពផលិតផល (ឧ.ពោត ត្រី ....) ។
- ការពង្រឹងសេវាកម្មដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍កសិកម្ម
- ពង្រីកផលិតកម្មបសុសត្វ និងសេវាសុខភាពសត្វ ចំណីអាហារ ការគ្រប់គ្រង និងបង្កើននូវផែនការកែច្នៃ
- ជំរុញការគ្រប់គ្រង និងផ្តើមនូវបច្ចេកទេសសមស្របដូចជា ការធ្វើកសិដ្ឋានចំរុះ ស្រូវ-ត្រី និង ពង្រីកការធ្វើវារីវប្បកម្ម
- ជំរុញបង្កើតសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ
- ជំរុញ និងពង្រឹងសមត្ថភាពគ្រប់កំរិតទាំងអស់នៃស្ថាប័នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# តើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ក្រសួងកសិកម្មយ៉ាងដូចម្តេច?

- **ទិសដៅ:** លើកស្ទួយវិស័យកសិកម្មដើម្បីជំរុញបង្កើនស្បៀងអាហារ និងមុខរបរដល់កសិករនៅជនបទ ។

- **គោលបំណង:**

គោលបំណងសំខាន់នៃកម្មវិធីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍន៍វិស័យកសិកម្មគឺ ៈ

- មានទំរង់ការច្បាប់មួយគ្រប់គ្រាន់គួបផ្សំនឹងភាពអំណោយផលនៃបរិស្ថានស្ថាប័ន
- កសាងសមត្ថភាព បង្កើនប្រព័ន្ធចំនេះដឹងដល់មន្ត្រីរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត
- ធ្វើប្រពលវប្បកម្ម ពហុវប្បកម្ម និងសន្តិសុខនៃផលិតផល
- ការគ្រប់គ្រងដោយនិរន្តរភាព និងការអភិរក្ស
- ជំរុញផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្មទៅក្នុងប្រព័ន្ធទីផ្សារ

# សកម្មភាពនៃការអភិវឌ្ឍន៍កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ

- មានទំរង់ការច្បាប់មួយគ្រប់គ្រាន់គួបផ្សំនឹងភាពអំណោយផលនៃបរិស្ថានស្ថាប័ន
  - ច្បាប់ស្តីពី ជលផល
  - ច្បាប់ស្តីពី ភូគតាមអនាម័យ
  - ច្បាប់ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ . . . ។ ល ។
- កសាងសមត្ថភាព បង្កើនប្រព័ន្ធចំនេះដឹងដល់មន្ត្រីរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត
  - ការកសាងសមត្ថភាព និងការងារផ្សព្វផ្សាយ
  - ការស្រាវជ្រាវ និង ការងារផ្សព្វផ្សាយកសិកម្ម
  - សម្ភារៈកសិកម្មមានគុណភាព

# សកម្មភាពនៃការអភិវឌ្ឍកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ (ត)

- កាត់បន្ថយការពឹងផ្អែកលើលក្ខខណ្ឌធម្មជាតិ
  - ពង្រឹងការត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធទឹក
  - គាំទ្រការធ្វើប្រពលវប្បកម្ម និងពហុវប្បកម្ម
  - ការអភិវឌ្ឍន៍ផលិតកម្ម និងបសុព្យាបាល
  - ការអភិវឌ្ឍន៍វារីវប្បកម្ម
- ការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានធម្មជាតិការអភិរក្ស
  - ការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានជលផល និងការបង្កើនជីវភាព
  - សហគមន៍នេសាទ និង
  - សហគមន៍ព្រៃឈើ



# ទិន្នផលកសិកម្ម

- បរិមាណផលត្រីសរុបឆ្នាំ ២០០៥ ចំនួន ៤១០ ៣០០ តោន កើនប្រមាណ ២៦ ភាគរយ ធៀបបរិមាណផលឆ្នាំ ២០០៤ ។ ដោយឡែក ផលនេសាទដាយត្រី ឆ្នាំ ២០០៥ ចំនួន ៣០ ០០០ តោន កើនប្រមាណ ១០០ ភាគរយ ធៀបបរិមាណផលឆ្នាំ ២០០៤ ។
- តុល្យភាពស្បៀង : សល់ជាង ១.៣១៩.៥០០ តោនអង្ករ គិតជាស្រូវជាង ២.០៦១.៨០០ តោន លើសឆ្នាំមុនចំនួនជាង ១.៤១១.៦០០ តោនស្រូវ ហើយខ្ពស់ជាងមធ្យមភាគ ១០ ឆ្នាំ កន្លងមក ចំនួន ១.៥០០.៩០០ តោន ។
- ដំណាំរួមផ្សំ : ផ្ទៃដីដាំដុះអនុវត្តបានជាង ២២៥.៥០០ ហាត លើសឆ្នាំមុនចំនួនជាង ៣២.៦០០ ហាត និងបរិមាណផលចំនួនជាង ១.០៣៩.៩០០ តោន និងទិន្នផល ៥.៥២២ តោន/ហ.ត ។
- ដំណាំឧស្សាហកម្ម : ផ្ទៃដីដាំដុះអនុវត្តបានជាង ២២៩.៩០០ ហាត លើសឆ្នាំមុនជាង ៥២.២០០ ហាត និងបរិមាណផលចំនួនជាង ៣៩១.៥០០ តោន និងទិន្នផល ១.៨០៩ តោន/ហ.ត ។

# ផលិតផលដំណាំស្រូវប្រៀបធៀបពីឆ្នាំ ២០០១ - ២០០៥

| កំរិតកំណត់ | ឯកតា | 2001 | 2002 | 2003 | 2004 | 2005 | មធ្យមភាគ ៥ឆ្នាំ |
|---|---|---|---|---|---|---|---|
| **ផ្ទៃដីដាំដុះប្រចាំឆ្នាំ** | **ហ.ត** | **2,240,917** | **2,137,125** | **2,314,285** | **2,374,175** | **2,443,530** | **2,302,006** |
| - វស្សា | - | 1,974,048 | 1,845,135 | 2,030,735 | 2,075,646 | 2,121,591 | 2,009,431 |
| - ប្រាំង | - | 266,869 | 291,990 | 283,550 | 298,529 | 321,939 | 292,575 |
| **ទិន្នផលប្រចាំឆ្នាំ** | **តោន/ហ.ត** | **2.070** | **1.916** | **2.101** | **1.977** | **2.479** | **2.109** |
| - វស្សា | - | 1.901 | 1.706 | 1.951 | 1.725 | 2.261 | 1.909 |
| - ប្រាំង | - | 3.204 | 3.181 | 3.175 | 3.536 | 3.901 | 3.399 |
| **បរិមាណផលប្រចាំឆ្នាំ** | **តោន** | **4,099,016** | **3,822,509** | **4,710,957** | **4,170,284** | **5,986,179** | **4,557,789** |
| - វស្សា | - | 3,275,953 | 2,915,900 | 3,837,957 | 3,132,581 | 4,734,300 | 3,579,338 |
| - ប្រាំង | - | 823,063 | 906,609 | 873,000 | 1,037,703 | 1,251,879 | 978,451 |
| **សេចក្តីត្រូវការស្បៀង** | **តោន** | **1,918,184** | **1,972,367** | **1,936,565** | **1,905,896** | **2,013,533** | **1,949,309** |
| **ស្បៀងសល់ ឬ ខ្វះ (អង្ករ)** | **តោន** | **+ 364,148** | **+ 156,006** | **+ 686,496** | **+ 416,118** | **+ 1,319,571** | **+ 588,468** |

# ក្រាហ្វិកប្រៀបធៀបទិន្នផលស្រូវរដូវវស្សា-ប្រាំង និងមធ្យមភាគប្រចាំឆ្នាំពីឆ្នាំ ២០០១ ដល់ ២០០៥



# ក្រាហ្វិកប្រៀបធៀបដំណាំរួមផ្សំ នៃផ្ទៃដីដាំដុះ និងបរិមាណផល ២០០១-២០០៥



# ក្រាហ្វិកប្រៀបធៀបដំណាំឧស្សាហកម្ម នៃផ្ទៃដីដាំដុះ និងបរិមាណផល ២០០១-២០០៥



# តើក្រសួងកសិកម្មមានទំនោរក្នុងការអភិវឌ្ឍន៍បន្តអ្វីខ្លះ ? (ត)

ជំរុញអនុវត្តផែនការសកម្មភាពតាមបណ្តាតាមអនុវិស័យ ស្របតាមផែនការយុទ្ធសាស្រ្ត អភិវឌ្ឍន៍វិស័យ  កសិកម្ម ឆ្នាំ ២០០៦-២០១០ ។

បន្តពិនិត្យរៀបចំកែលំអរចនាសម្ព័ន្ធរបស់ក្រសួង និងការកសាងសមត្ថភាពអភិវឌ្ឍន៍ធនធានមនុស្ស ទៅតាមបណ្តាអង្គភាពក្រោមឳវាទក្រសួង ឱ្យស្របតាមដំណើរការអភិវឌ្ឍន៍បច្ចុប្បន្ន ។

លើកកំពស់ការអភិវឌ្ឍន៍ស្ថាប័ន ដោយបន្តរៀបចំកែសំរួលតួនាទីភារកិច្ចមន្ត្រីរាជការ ឱ្យកាន់តែមានសមត្ថភាព និងកែទម្រង់រដ្ឋបាលគ្រប់គ្រងបុគ្គលិក ដើម្បីប្រសិទ្ធភាពការងារ និងបន្តការកសាងលិខិតបទដ្ឋានច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ ។

# តើក្រសួងកសិកម្មមាននាទីអ្វីខ្លះ ? (ត)

- កែទម្រង់ការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មឱ្យបានសមស្របតាមរចនាសម្ព័ន្ធរបស់ក្រសួង
- លើកកំពស់ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍វិស័យកសិកម្មដោយបង្កើននូវការអភិវឌ្ឍន៍ផ្នែកឯកជនភាវូ-នីយកម្មកសិកម្ម និងបង្កើនការលើកទឹកចិត្តដល់ការវិនិយោគលើវិស័យកសិកម្ម ព្រមទាំងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ។
- បន្តពង្រឹងការគ្រប់គ្រង និងសម្របសម្រួលឱ្យបានល្អលើផ្នែកវិនិយោគឯកជនក្នុងវិស័យកសិកម្ម ។
- លើកកំពស់លើបញ្ហាសន្តិសុខស្បៀង និងបង្កើនផលិតកម្មស្បៀងពិសេស គឺដំណាំស្រូវ និងដំណាំស្បៀងរួមផ្សំ

# តើក្រសួងកសិកម្មមានទំនោរក្នុងការអភិវឌ្ឍន៍បន្តអ្វីខ្លះ ? (ត)

- ចូលរួមអនុវត្តគោលនយោបាយទឹកកសិកម្ម ដោយពង្រីកប្រពន្ធ័ស្រោចស្រពបន្ថែម និងជួសជុលប្រព័ន្ធស្រោចស្រព ដែលមានស្រាប់ព្រមទាំងពង្រឹងការគ្រប់គ្រង ។
- បង្កើនរដូវដាំដុះ និងពង្រីកផ្ទៃដីផលិតកម្មកសិកម្មបន្ថែមនៅលើដី ដែលបានបោសសំអាតមីនរួច និងដីបោះបង់ចោលខ្សោះជីជាតិ ។
- កែលំអប្រព័ន្ធដាំដុះរួមទាំងការបង្កើនមុខដំណាំដាំដុះ ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីតាមគោលការណ៍ ភូមិមួយផលិតផលមួយមុខ ។
- ជំរុញការអនុវត្តប្រពន្ធ័កសិកម្មចំរុះ តាមរយៈការបង្កើនគុណភាពដី ការការពារដំណាំ និងការជ្រើសរើសពូជដែលផ្តល់ទិន្នផលខ្ពស់ ។

# តើក្រសួងកសិកម្មមានតំនៅរក្នុងការអភិវឌ្ឍន៍បន្តអ្វីខ្លះ ? (ត)

- ជំរុញការអនុវត្តយន្តបនីយកម្មដែលសមស្រប និងបច្ចេកវិទ្យាផលិតកម្មប្រមូលផលទំនើប ដោយផ្តើមចេញពីកសិដ្ឋានគំរូ ។
- ពង្រឹងសេវាកម្មគាំទ្រកសិកម្មសំខាន់ៗ រួមមានទីផ្សារកសិផល កម្មវិធីអប់រំផ្សព្វផ្សាយ ការស្រាវជ្រាវ និងពង្រឹងសហគមន៍អភិវឌ្ឍន៍កសិកម្ម ។
- ជំរុញការរៀបចំប្រពន្ធ័ហិរញ្ញវត្ថុជនបទសំរាប់ផ្តល់ឥណទានដល់កសិករប្រើប្រាស់លើការងារផលិតកម្មកសិកម្ម ។
- ពង្រឹង និងពង្រីការងារផលិតកម្មសត្វ និងកែច្នៃកាកសំណល់សត្វ ថែរក្សាសុខភាពសាធារណៈលើសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

# តើក្រសួងកសិកម្មមាននំនោរក្នុងការអភិវឌ្ឍន៍បន្តអ្វីខ្លះ ? (ត)

- បង្កើនគុណភាពកសិផល និងជំរុញការអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្ម និងម្ហូបអាហារកែច្នៃ ដើម្បីបង្កើនតំលៃបន្ថែម និងប្រាក់ចំណូលកសិករ ។
- ចូលរួមលើការកែទំរង់ប្រើប្រាស់ដីធ្លី និងទប់ស្កាត់ការកាប់រានដីព្រៃ និងការកាប់យកដីកាន់កាប់ដោយអនាធិបតេយ្យ ។
- កែទំរង់វិស័យជលផលដោយពង្រឹងការគ្រប់គ្រងលើការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងលុបបំបាត់សកម្មភាពធ្វើនេសាទខុសច្បាប់រួមមានការបំបាត់ឧបករណ៍ហាមឃាត់គ្រប់ប្រភេទ និងការកាប់បំផ្លាញព្រៃលិចទឹក ។
- កែទំរង់ព្រៃឈើដោយពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ និងបន្តការលប់បំបាត់ភាពអនាធិបតេយ្យលើវិស័យព្រៃឈើ និងសត្វព្រៃ ។


សូមអរគុណ